ពង្រាងជំនួយស្មារតី

# សិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់
# ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន
# (កម្ពុជា - ឡាវ - មីយ៉ាន់ម៉ាន និងវៀតណាម)

## I-**ប្រព័ន្ធគ្រប់គ្រងព្រំដែន**

ប្រព័ន្ធគ្រប់គ្រងព្រំដែននៃព្រះរាជាណាចក្រកម្ពុជាមាន ៣ប្រភេទ

**១/ ច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ** ចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានចំនួន ២៦ ៖

- ច្រកទ្វារកំពង់ផែអន្តរជាតិ ចំនួន ០៤
- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន ០៣
- ច្រកទ្វារព្រំដែនអន្តរជាតិ ចំនួន ១៩
  - ➡ជាប់ប្រទេសវៀតណាម ចំនួន ១១
  - ➡ជាប់ប្រទេសថៃ ចំនួន ០៧
  - ➡ជាប់ប្រទេសឡាវ ចំនួន ០១

- ច្រកទ្វារទាំង២៦នេះ គឺជាច្រកទ្វារដែលបម្រើសេវាជាអន្តរជាតិ ដល់អ្នកដំណើរគ្រប់ប្រទេសដែលមានបំណងចេញ-ចូលកម្ពុជា ហើយច្រកទ្វារទាំង២៦នេះ យើងបានបំពាក់ប្រព័ន្ធគ្រប់គ្រងព្រំដែនកម្ពុជា (CBMS)។

**២/ ច្រកទ្វេភាគី**

- ច្រកទ្វារទ្វេភាគី គឺបង្កើតឡើងដោយមានការព្រមព្រៀង រវាងប្រទេសជាប់ព្រំដែន ហើយច្រកទ្វារទ្វេភាគីនេះ មានការប្រថាប់ត្រាចេញ-ចូល ដូចច្រកទ្វារអន្តរជាតិដែរ តែមានលក្ខណៈក្នុងក្របខ័ណ្ឌត្រឹមប្រទេសនិងប្រទេសជាប់ព្រំដែន មិនអនុញ្ញាតឲ្យមានប្រទេសទី៣ចេញ-ចូលនៅច្រកទ្វេភាគីនេះទេ។ វិសាលភាពច្រកទ្វារទ្វេភាគីនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្នងការដ្ឋាននគរបាលខេត្ត ចំណុះអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**៣/ ច្រកទ្វារតំបន់**

- ច្រកទ្វារតំបន់ គឺបង្កើតឡើងដោយមានការព្រមព្រៀង រវាងប្រទេសជាប់ព្រំដែន ហើយច្រកទ្វារតំបន់នេះ មិនមានការប្រថាប់ត្រាចេញ-ចូលទេ ហើយការចេញ-ចូលធ្វើដំណើរត្រឹមកំរិតក្នុងតំបន់ជាប់ព្រំដែន។ វិសាលភាពច្រកតំបន់នេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្នងការដ្ឋាននគរបាលខេត្ត ចំណុះអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**សូមគោរពបញ្ជាក់ផងដែរថា** ➢ក្រោយពីមានការសហការជាមួយអង្គការ IOM យើងបានសាកល្បងរៀបចំប្រព័ន្ធគ្រប់គ្រងពលករខ្មែរដែលចេញ-ចូលតាមច្រកទ្វារព្រំដែនអន្តរជាតិ ដោយប្រើប្រាស់ទិន្នន័យសរុបពីអត្តសញ្ញាណប័ណ្ណពលរដ្ឋខ្មែរ ដោយប្រើប្រាស់បាកូដ (Barcode) ងាយស្រួលក្នុងការគ្រប់គ្រងការចេញ-ចូល ហើយប្រព័ន្ធនេះឈ្មោះ MIDAS ដែលទើបតែបានដាក់ដំណើរការនៅច្រកទ្វារព្រំដែនអន្តរជាតិដូងយើងនឹងបន្តទៅច្រកទ្វារផ្សេងៗទៀត នៅពេលក្រោយ ។

➢ការផ្តល់ទិដ្ឋាការនៅមាត់ច្រក ពេលមកដល់ដំបូង (Visa on Arrival)។

## II-ឧបករណ៍ច្បាប់

ពាក់ព័ន្ធនឹងបទបង្ហាញនិយាយអំពីឧបករណ៍ច្បាប់ សម្រាប់ដំណើរការរបស់ប្រព័ន្ធគ្រប់គ្រងព្រំដែននៃព្រះរាជាណាចក្រកម្ពុជា សម្រាប់អនុវត្ត ៖

១/ អំពីលក្ខខណ្ឌរបស់មន្ត្រីបម្រើការងារនៅច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ បានបំពេញគ្រប់លក្ខខណ្ឌតាមមាត្រា៦០ និងមាត្រា៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

២/ អំពីឧបករណ៍គតិយុត្តិច្បាប់

➢ច្បាប់ស្តីពីអន្តោប្រវេសន៍
➢ច្បាប់ព្រហ្មទណ្ឌ
➢អនុក្រឹត្យលេខ ១០៩
➢អនុក្រឹត្យលេខ ៦៤
➢អនុក្រឹត្យលេខ ១២៣
➢សេចក្តីជូនដំណឹងលេខ ៩៦០

## III-កិច្ចសហការ

➢យោងកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន និងលើលិខិតបទដ្ឋានគតិយុត្តិ ដែលមានជាធរមានដូចជា ច្បាប់ស្តីពីអន្តោប្រវេសន៍ - ច្បាប់ព្រហ្មទណ្ឌ - ច្បាប់នានា នៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងអនុក្រឹត្យលេខ១០៩ - អនុក្រឹត្យលេខ ៦៤ - អនុក្រឹត្យលេខ១២៣ ដែលបានចែងអំពីតួនាទី និងសិទ្ធិច្បាស់លាស់ ដូចនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍មានការសហការដើម្បីបង្ការ និងបង្ក្រាបទប់ស្កាត់រាល់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែន និងបទល្មើសដែលបំផ្លាញដល់សន្តិសុខកម្ពុជា ជាកំរិតសហការៈ

១/ ស្ថាប័នផ្ទៃក្នុងប្រទេស
២/ ស្ថាប័នអន្តរជាតិ
៣/ ស្ថាប័នឯកជន

ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២០

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍**